ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អយ្យការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Office of the Co-Prosecutors of the Extraordinary Chambers in the Courts of Cambodia
Parquet auprès des Chambres Extraordinaires au sein des Tribunaux Cambodgiens

**សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជតក**
Case File/Dossier N°. 002/19-09-2007-ECCC/SC

---

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ៖ | ក្រសួងមហាផ្ទៃ |
| ថ្ងៃដាក់៖ | ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ |

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-23, 14:23
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

**សំណើសុំការអនុវត្តទោស**

---

**អ្នកដាក់ឯកសារ៖**

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Fergal GAYNOR (បម្រុង)

**អ្នកទទួលឯកសារ៖**

**អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ**

**ឧណ្ឌិត**

ខៀវ សំផន

**<u>ចម្លងជូន៖</u>**

**អង្គជំនុំជម្រះតុលាការកំពូល**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ្ជ អង្គ
Falguni DEBNATH

**ប្រធានរដ្ឋបាលស្តីទី**

ឯ.ឧ ក្រាញ់ តូនី

**អនុប្រធានរដ្ឋបាល**

Knut ROESANDHAUG

**ប្រធានមន្ទីរឃុំឃាំង អវតក**

ម៉ៅ សុភារម្យ

**មន្ត្រីទទួលបន្ទុកផ្នែកគាំពារការការពារក្តី**

គង់ សុគន្ធ (Kong Sokun)

**មេធាវីការពារក្តីទណ្ឌិត**

គង់ សំអុន
Anta GUISSÉ

យើង សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**បានឃើញ** ការចេញសាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ប្រឆាំង ខៀវ សំផន នៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយអង្គជំនុំជម្រះតុលាការកំពូល (“អជតក”)[1] ដែលក្នុងនោះ អជតក បានតម្កល់ ការផ្ដន្ទាទោសដាក់ពន្ធនាគារ ខៀវ សំផន អស់មួយជីវិត[2]។

**បានឃើញ** ការចេញសេចក្ដីសង្ខេបនៃសាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ដោយ អជតក[3] (“សេចក្ដីសង្ខេបនៃសំណុំរឿង ០០២/០២”) រួមទាំងផ្នែកសម្រេចសេចក្ដី បានប្រកាសអំពីសាលដីកាស្ថាពរ លើបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន និង សហព្រះរាជអាជ្ញា នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ដែលក្នុងនោះ អជតក បានតម្កល់ការផ្ដន្ទាទោសដាក់ពន្ធនាគារ ខៀវ សំផន អស់មួយជីវិតបន្ថែមទៀត ដែលត្រូវអនុវត្ត ទោសដំណាលគ្នាជាមួយនឹងទោសដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង ០០២/០១[4]។

**បានឃើញ** ច្បាប់ចម្លងនៃសាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដែលសាលដីកាលើ បណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦[5]។

**បានឃើញ** ការចេញសាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ដែល អជតក បានតម្កល់ការផ្ដន្ទាទោសដាក់ពន្ធនាគារ ខៀវ សំផន អស់មួយជីវិតបន្ថែមទៀត ដែលត្រូវអនុវត្ត ទោសដំណាលគ្នាជាមួយនឹងទោសដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង ០០២/០១ និងបង្គាប់ឲ្យ ខៀវ សំផន ត្រូវបន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក រហូតដល់មានការរៀបចំសមស្របចប់សព្វគ្រប់ក្នុង ការបញ្ជូនគាត់ទៅក្រោមការគ្រប់គ្រងរបស់អជ្ញាធរជាតិ។[6]

---

1 ឯកសារ **F36** សាលដីកាលើបណ្ដឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ (“សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១”)។

2 ឯកសារ **F36** សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២១ ផ្នែកសម្រេចសេចក្ដី។ ឯកសារ **E313** សាលក្រម កថាខណ្ឌ ១១០៧ ផ្នែកសម្រេចសេចក្ដី។

3 ឯកសារ **F76.1** សេចក្ដីសង្ខេបនៃសាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ (“សេចក្ដីសង្ខេបនៃសំណុំរឿង ០០២/០២”)។

4 ឯកសារ **F76.1** សេចក្ដីសង្ខេបនៃសំណុំរឿង ០០២/០២ កថាខណ្ឌ ១០៤ ផ្នែកសម្រេចសេចក្ដី។ ឯកសារ **E465** សាលក្រម នៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៤៣៥៩-៤៣៦០, ៤៤០២, ផ្នែកសម្រេចសេចក្ដី។

5 ភ្ជាប់ជា **ឧបសម្ព័ន្ធ I**។

6 **F76** សាលដីកាលើបណ្ដឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ (“សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២”) ។

**បានឃើញ** ច្បាប់ចម្លងនៃសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដែលសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរនៅ [២៣ ខែធ្នូ ឆ្នាំ២០២២[7]។

**បានឃើញ** វិធាន ១១៣(១) នៃវិធានផ្ទៃក្នុង ("វិធាន")[8] ដែលចែងក្នុងផ្នែកពាក់ព័ន្ធថា "ការអនុវត្តទោសត្រូវធ្វើតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញា" ហើយវិធាន ១១៣(២) នៃវិធាននេះ ដែលចែងក្នុងផ្នែកពាក់ព័ន្ធថា "សហព្រះរាជអាជ្ញាធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានចូលជាស្ថាពរ"។

**បានឃើញ** កាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ក្នុងការផ្តល់លក្ខខណ្ឌនៃការឃុំឃាំងដែលស្របទៅនឹងបទដ្ឋានសិទ្ធិមនុស្សជាមូលដ្ឋាន រួមទាំងកាតព្វកិច្ចខ្ពស់ពាក់ព័ន្ធនឹងអ្នកទោសដែលមានវ័យចាស់ជរា រួមទាំងអ្នកមានបញ្ហាសុខភាពដូច ខៀវ សំផន[9]។

**បានឃើញ** សេចក្តីសម្រេចរបស់ អជតក លើសំណើររបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញាស្តីពីផែនការលក្ខខណ្ឌនៃការឃុំឃាំង ដែលក្នុងនោះ អជតក បានសម្រេចថា "ប្រសិនបើ [...] ការរៀបចំដែលធានាដល់លក្ខខណ្ឌឃុំឃាំងឲ្យបានពេញលេញសម្រាប់ ខៀវ សំផន នៅមិនទាន់បានបញ្ចប់សព្វគ្រប់នៅត្រឹមពេលមានការជូនដំណឹងអំពីសាលដីកាលើបណ្តឹងសាទុក្ខ ដែលមានសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនៅក្នុងសំណុំរឿង ០០២/០២ ខៀវ សំផន មិនត្រូវបានផ្ទេរចេញទេ លុះត្រាតែមានការរៀបចំឲ្យបានសមស្របដោយសហព្រះរាជអាជ្ញា" ដោយសហការជាមួយអាជ្ញាធរជាតិ[10]។

---

7 ភ្ជាប់ជា **ឧបសម្ព័ន្ធ II**។

8 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី ៩) ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

9 ឯកសារ **F177/1/1** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញាស្តីពីផែនការលក្ខខណ្ឌនៃការឃុំឃាំង ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ កថាខណ្ឌ ១៦។ ច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១១/០២១ មាត្រា ២(ខ) និង ៣៨។ មហាសន្និបាតអង្គការសហប្រជាជាតិ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ អង្គការសហប្រជាជាតិ ស៊េរីសន្ធិសញ្ញា វ៉ុល 999 ទំព័រ ១៧១ មាត្រា ៧ និង ១០។ វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ សម្រាប់ការប្រព្រឹត្តិចំពោះអ្នកទោស សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 70/175 ឧបសម្ព័ន្ធ អនុម័តនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ វិធាន ១-៣, ១៥-១៦, ១៨, ២៤-២៧, ៣០, ៥៨។

10 ឯកសារ **F177/1/1** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញាស្តីពីផែនការលក្ខខណ្ឌនៃ

**ស្នើសុំ** អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ដើម្បីកំណត់កន្លែងឃុំឃាំងដែលសមរម្យ ដើម្បីឲ្យ ខៀវ សំផន អនុវត្តទោសដែលនៅសេសសល់ ធ្វើការកែសម្រួលផ្នែករូបវន្តនៃពន្ធនាគារនោះ និងផ្ដល់ផែនការសម្រាប់បន្តការថែរក្សាសុខភាពដល់ ខៀវ សំផន និងការថែទាំប្រចាំថ្ងៃដល់រូបគាត់ក្នុងពេលឃុំឃាំង។ និង

**ស្នើសុំបន្ថែមទៀត** ថា ខៀវ សំផន គួរបន្តស្ថិតក្នុងការឃុំឃាំងនៅមន្ទីរឃុំឃាំង អវតក រហូតដល់ពេលដែលសហព្រះរាជអាជ្ញា និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃឯកភាពគ្នាទៅលើពន្ធនាគារដែលសមរម្យដើម្បីឃុំឃាំង ខៀវ សំផន សម្រាប់ការអនុវត្តទោសដែលនៅសេសសល់របស់គាត់។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ | ជា លាង<br>សហព្រះរាជអាជ្ញា | រាជធានីភ្នំពេញ | [signature] |
| | Fergal GAYNOR<br>(បម្រុង) | | [signature] |

ការឃុំឃាំង ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ កថាខណ្ឌ ២៣។